

រូបខាងលើនេះ ៖ សម្តេចនរោត្តម-សីហនុ ជាមួយឧត្តមសេនិយញឹក-ជូឡុង កំពុងបង្ហាញដល់ពួកអ្នកកាសែតបរទេស នូវផែនទីជំរកកងទ័ពយៀកកុង-យៀកណាមខាងជើង ស្ថិតនៅតាមតំបន់ព្រំដែនទិសខាងកើតប្រទេសកម្ពុជា (ថ្ងៃទី២៨ មិនា ឆ្នាំ១៩៦៩)



រូបខាងលើនេះ ៖ សន្និសិទរបស់សម្តេចសីហនុនៅព្រះដំណាក់ចំការមន (ថ្ងៃទី១៧ ឧសភា ឆ្នាំ១៩៦៩) បង្ហាញដល់ពួកអ្នកកាសែតបរទេសអំពីរូបភាពជំរកកងទ័ពយៀកកុង-យៀកណាមខាងជើង នៅក្នុងខេត្តរតនៈគីរី

ខាងក្រោមនេះ គឺការដកស្រង់ចេញពីទីភ្នាក់ងារពត៌មានបារាំង AFP កាលពីថ្ងៃទី២៨ មិនា ឆ្នាំ១៩៦៩ ស្តីអំពីសន្និសិទកាសែតរបស់សម្តេចសីហនុ នៅឯព្រះដំណាក់ចំការមន (ក្រុងភ្នំពេញ) ៖

## សន្និសិទកាសែតរបស់សម្តេចនរោត្តម-សីហនុ (ថ្ងៃទី២៨ មិនា ឆ្នាំ១៩៦៩)

«ពួកកុម្មុយនិស្តយៀកណាម បានចូលកាន់តែច្រើនឡើងៗក្នុងស្រុករបស់យើង ។ ខ្ញុំពុំអាចលាក់បំបាំងបានតទៅទៀតទេ ។ ពេលនេះគឺជាពេលដែលមតិពិភពលោកត្រូវតែដឹង», នេះជាសេចក្តីថ្លែងប្រកាសកាលពីល្ងាចថ្ងៃសុក្រទៅកាន់ពួកអ្នកកាសែត របស់សម្តេចនរោត្តម-សីហនុ នៅចំពោះមុខឧត្តមសេនិយញឹក-ជូឡុង អគ្គមេបញ្ជាការកងទ័ពខ្មែរ, ឧត្តមសេនិយលន់-នល់ ប្រធានក្រុមប្រឹក្សាស្តីទីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ព្រមទាំងវរៈសេនីយ៍ឯកខ្មែរជាច្រើនរូបទៀត ។

នេះជាលើកទី១ហើយ នៅចំពោះមុខពួកអ្នកកាសែត ដែលសេនាធិការរបស់ព្រះអង្គ បានបង្ហាញឲ្យឃើញនូវផែនទីពិស្តារ ស្តីអំពីទីតាំងរបស់កុម្មុយនិស្តនៅក្នុងទឹកដីខ្មែរ។ ឯកភាពទាំងនោះ ចាប់ពីថ្នាក់កងវរៈសេនាធំ ដល់កងវរៈសេនាតូច រហូតដល់កងអនុសេនាធំ បានត្រូវគេពង្រាយតាមបណ្តោយព្រំដែន ចាប់ពីទិសព្យសានផៃខេត្តរតនៈគីរី ចុះរហូតទៅដល់សមុទ្រ ។

ពួកអ្នកកាសែតត្រូវបានសន្យាថា មិនបញ្ជូនដំណឹងទៅក្រៅឲ្យដឹងពីទីកន្លែងជ្រកពួនពិតប្រាកដទាំងអស់នោះទេ «គឺដើម្បីចៀសវាងការទម្លាក់គ្រាប់បែក ប៉ះពាល់ទៅលើផ្ទះសំបែងនៃប្រជារាស្ត្ររបស់យើង និងពួកជនជាតិវៀតណាម ដែលចូលមកពុំមែនជាយុទ្ធជន», នេះជាសេចក្តីថ្លែងបញ្ជាក់របស់ព្រះអង្គ ។ ក៏ប៉ុន្តែគួរកត់សម្គាល់ថា នៅលើទឹកដីខ្មែរគឺពិតជាមានទីតាំងរបស់វៀតណាមដូចជា គិលានដ្ឋាន, ជំរំសំរាក និងជាមួយគ្នាផងដែរនោះ នៅក្នុងខេត្តមួយនៅទិសព្យសាន មានមូលដ្ឋានចំនួន២ឬ៣ថែមទៀតផង ។៚

( កំណត់ ៖ ឯកសារនេះ ដកស្រង់ចេញពី DOCUMENTS sur l'agression Vietcong et Nord-Vietnamienne contre le Cambodge (1970) របស់ក្រសួងឃោសនាការជាតិក្រុងភ្នំពេញ ) ។



រូបខាងលើនេះ ៖ សន្និសិទរបស់សម្តេចសីហនុនៅព្រះដំណាក់បូក-គោ (ថ្ងៃទី២៣ ឧសភា ឆ្នាំ១៩៦៩) បង្ហាញដល់ពួកអ្នកកាសែតបរទេសអំពីរូបភាពទាហានទ័ពយៀកកុង-យៀកណាមខាងជើង ដែលកងយោធពលខេមរភូមិន្ទចាប់ខ្លួនបាននៅក្នុងខេត្តមណ្ឌលគីរី



ទាហានយៀកកុងទាំង៣នាក់ ដែលខ្មែរចាប់បាននៅទន្លេសេសាន